សន្លឹកព័ត៌មាន

# យន្តការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ (យូ.ភី.អ) នៃប្រទេសកម្ពុជា (ជុំទី៤) សិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ (សូជីអេសស៊ី - SOGIESC) និងសិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជ

*របាយការណ៍រួមនេះរៀបចំដោយ អង្គការសហគមន៍ឥន្ទធនូកម្ពុជា (RoCK) និងមានការចូលរួមរៀបចំដោយអង្គការជីវិតស្រស់បំព្រង (BLO) មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) មូលនិធិមីក្រូឥន្ទធនូអន្តរជាតិ (MRIF) អង្គការយេនឌ័រនិងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC) អង្គការសីលការកម្ពុជា (SILAKA) អង្គការនារីដើម្បីសន្តិភាព (WPM) អង្គការក្លាហាន (Klahaan) អង្គការថែទាំសុខភាពគ្រួសារកម្ពុជា (RHAC) អង្គការបណ្តាញការងារស្ត្រីរួបរួមគ្នា (WNU) សមាគមស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ និងអ្នកអន្តរភេទតំបន់អាស៊ី (ILGA Asia) មូលនិធិសម្ព័ន្ធអាស៊ីប៉ាស៊ីហ្វិកដើម្បីសុខភាពផ្លូវភេទបុរស (APCOM) អង្គការសម្ព័ន្ធអាស៊ីប៉ាស៊ីហ្វិកដើម្បីសិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជ (APA) បណ្តាញអ្នកប្តូរយេនឌ័រតំបន់អាស៊ីប៉ាស៊ីហ្វិក (APTN) អង្គការមជ្ឈមណ្ឌលធនធាននិងស្រាវជ្រាវដើម្បីស្ត្រីតំបន់អាស៊ីប៉ាហ្វិក (ARROW) សមាគមស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ និងអ្នកអន្តរភេទសកលលោក (ILGA World) សមាគមដើម្បីសិទ្ធិផ្លូវភេទនិងបន្តពូជសម្រាប់គ្រប់គ្នា (RFSU) ភ្នាក់ងារដើម្បីអភិវឌ្ឍន៍ស្ត្រីអន្តរជាតិ (IWDA) និងក្រុមស្ម័គ្រចិត្តដែលជាយុវជនអ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រទេសកម្ពុជា ដែលបានចូលរួមការដាក់របាយការណ៍រួមនេះមានដូចជា៖ ក្តីស្រឡាញ់គឺចម្រុះ (LID) និងទីសុវត្ថិភាពបាត់ដំបង (SSBTB)។*

**របាយការណ៍រួមរបស់អង្គការសង្គមស៊ីវិល នៃយន្តការពិនិត្យឡើងវិញជាសកលតាមកាលកំណត់(យូ.ភី.អ)ជុំទី៤ ស្តីពីសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ (សូជីអេសស៊ី) និងសិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជរបស់កម្ពុជា បង្ហាញពីការប៉ាន់ប្រមាណនៃការវិវឌ្ឍ ដែលឈានទៅកាន់ការអនុវត្ត អនុសាសន៍ទាំង៩នៃរបាយការណ៍ យូ.ភី.អ.ជុំទី៣ អំពីសិទ្ធិសូជីអេសស៊ី និងសិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជ ដែលប្រទេសកម្ពុជាបានទទួលយក ព្រមទាំងទទួលស្គាល់ពីចំណុចវិជ្ជមាន ក៏ដូចជាចន្លោះប្រហោងនៃការអនុវត្តផងដែរ។ ការដាក់របាយការណ៍រួម យូ.ភី.អ ជុំទី៤ របស់បណ្តាញសង្គមស៊ីវិលនេះក៏ស្នើនូវអនុសាសន៍អាទិភាព ដើម្បីធានាបានថាប្រទេសកម្ពុជាការពារសិទ្ធិ សូជីអេសស៊ី សិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជ ក៏ដូចជាសមភាពសិទ្ធិស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ (LGBT+) ប្រកបដោយប្រសិទ្ធិភាព ស្របជាមួយគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព "មិនទុកនរណាម្នាក់ចោល" ។**

## ទិដ្ឋភាពទូទៅនៃស្ថានភាពសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា (LGBT+) ក្នុងប្រទេសកម្ពុជា

- នាប៉ុន្មានឆ្នាំចុងក្រោយនេះ ការបង្ហាញវត្តមាននៃអ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រទេសកម្ពុជាមានការកើនឡើង ដែលពួកគេមានភាពក្លាហានក្នុងការចេញមុខដោយផ្ទាល់ និងនៅលើបណ្តាញសង្គមផងដែរ។ ការលើកកម្ពស់ការយល់ដឹងនិងទទួលស្គាល់ ជាសាធារណៈចំពោះ អ្នក ស្រឡាញ់ភេទដូចគ្នាក៏មានការរីកចម្រើនជាងមុន ដោយមួយផ្នែកកើតចេញពីការអប់រំ និងលើកកម្ពស់ការយល់ដឹងរបស់សមាជិក សហគមន៍ អ្នកស្រឡាញ់ភេទដូចគ្នានិងអង្គការសង្គមស៊ីវិល។ ការអំពាវនាវជាសាធារណៈពីសំណាក់អាជ្ញាធរមូលដ្ឋាន និងតំណាងរដ្ឋាភិបាលថ្នាក់ជាតិ ក្នុងការជំរុញលើកទឹកចិត្តមិនឱ្យមានការរើសអើង ក៏ដូចជាកំណើននៃប្រព័ន្ធផ្សព្វផ្សាយសារព័ត៌មានដែលមានភាពវិជ្ជមានផងដែរ។
- ប្រទេសកម្ពុជាមិនមានការដាក់ទោសទណ្ឌទៅលើប្រជាជនដែលមាននិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រចម្រុះ ឬប្រជាជនអ្នកស្រឡាញ់ភេទដូចគ្នានោះទេ (LGBT+) ហើយក៏មិនទាន់មានការការពារផ្នែកច្បាប់ជាក់លាក់ដែរ។ ទោះជាការគោរព លើកកម្ពស់ និងការការពារសិទ្ធិមនុស្សរបស់ប្រជាជនអ្នកស្រឡាញ់ ភេទដូចគ្នាមានភាពប្រសើរឡើងយ៉ាងណាក៏ដោយ អ្នកស្រឡាញ់ភេទដូចគ្នានៅប្រទេសកម្ពុជានៅតែបន្តជួបប្រទះការរើសអើងផ្នែកច្បាប់និងសង្គម ផ្អែកលើ និន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទរបស់ពួកគេក្នុងទម្រង់នានាដូចជា៖ ១)ការផាត់ចេញគូស្រករភេទដូចគ្នាពីអាពាហ៍ពិពាហ៍ស្របច្បាប់ក្នុងពេលបច្ចុប្បន្ន (ការដែលមិនអាចចុះសំបុត្រអាពាហ៍ពិពាហ៍គឺជាការបដិសេធគូស្រករភេទដូចគ្នាពីកិច្ចការពារដែលចាំបាច់និងការទទួលស្គាល់គូស្រករភេទដូចគ្នា និងក្រុមគ្រួសារ ហើយរារាំងការទទួលបានសិទ្ធិសុំកូនពេញលេញរបស់ពួកគេ) ២) កង្វះការទទួលស្គាល់ផ្នែកច្បាប់ចំពោះការកំណត់អត្តសញ្ញាណយេនឌ័រផ្ទាល់ខ្លួនរបស់អ្នកប្តូរយេនឌ័រ និងបុគ្គលដែលមានអត្តសញ្ញាណយេនឌ័រចម្រុះ និង ៣) បទពិសោធនៃការរើសអើងទៅលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទដែលនៅតែកើតមាននិងជាឧបសគ្គនៃការទទួលបានបរិយាបន្នសង្គម (ការរួមបញ្ចូល) ទាំងក្នុងក្រុមគ្រួសារ ការអប់រំ វិស័យការងារ និងសុខាភិបាល ដោយសារតែកង្វះកិច្ចការពារផ្នែកច្បាប់និងគោលនយោបាយប្រឆាំងនឹងការរើសអើងទៅលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ។

## បរិបទ យូ.ភី.អ និងសេចក្តីសង្ខេប យូ.ភី.អ ជុំទី៣

- **ក្នុងដំណើរការយូ.ភី.អជុំទី៣ ក្នុងឆ្នាំ២០១៩** រាជរដ្ឋាភិបាលកម្ពុជាទទួលបាននិងទទួលយកអនុសាសន៍ចំនួន៩ អំពី**កិច្ចការពារសិទ្ធិសូជីអេសស៊ី និងសិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជ** ដែលផ្តោតលើកំណែទម្រង់ផ្នែកច្បាប់និងគោលនយោបាយចំនួន៣ដូចជា៖ **វិសោធនកម្មច្បាប់ពាក់ព័ន្ធ ដើម្បីអនុញ្ញាតឱ្យមានសមភាពអាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នា (LGBT+)** ***(អនុសាសន៍លេខ ១១០.៥៥ ពីកាណាដា ១១០.៥១ ពីហូឡង់ និង***

*១១០.៨៧ ពីអ៊ីស្លង់)* **អនុញ្ញាតឱ្យមានការទទួលស្គាល់ស្របច្បាប់លើអត្តសញ្ញាណយេនឌ័រសម្រាប់បុគ្គលអ្នកប្តូរយេនឌ័រ** *(អនុសាសន៍លេខ១១០.៥៤ ពីអ៊ីស្លង់)* **បង្កើតច្បាប់និង គោលនយោបាយការពារពីការរើសអើងនិងអំពើហិង្សាផ្អែកលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ ប្រកបដោយ ប្រសិទ្ធិភាព***(អនុសាសន៍លេខ១១០.៤៥ ពីអ៊ីស្លង់ ១១០.៥២ ពីស៊ុយអ៊ែត ១១០.៥៤ ពីអូស្ត្រាលី ១១០.៥០ពីម៉ិចស៊ីកូ ១១០.៥៣ ពីអ៊ុយរូហ្គាយ)*។

- ការទទួលយកអនុសាសន៍ទាំង៩ លើសិទ្ធិសូជីអេសស៊ី និងសិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជ ក្នុងយូ.ភី.អជុំទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា បានបង្ហាញការប្តេជ្ញាចិត្តវិជ្ជមានមួយរបស់កម្ពុជា ក្នុងការធានាបាននូវការការពារដែលមានសមភាព និងសមធម៌សម្រាប់អ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រទេសកម្ពុជា។
- ការទទួលយកអនុសាសន៍ទាំងនេះ បានចូលរួមចំណែកគួរឱ្យកត់សម្គាល់ក្នុងការបង្កើតបែបផែនវិជ្ជមានមួយ ដែលជំរុញឱ្យមានកិច្ចសន្ទនាជាបន្តបន្ទាប់ជាមួយ ភាគីពាក់ព័ន្ធសំខាន់ៗនៅក្នុងប្រទេសកម្ពុជា (ជាពិសេសរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសង្គមស៊ីវិលដែលធ្វើការលើសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា)អំឡុងឆ្នាំ២០១៩-២០២៣ ដើម្បីជំរុញនិងបោះជំហានវិជ្ជមានឈានទៅការអនុវត្តអនុសាសន៍យូ.ភី.អជុំទី៣ អំពីសិទ្ធិសូជីអេសស៊ី និងសិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជ ហើយធានាបាននូវសមភាពសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា( សូមមើលផ្នែកខាងក្រោម )។
- ទោះជាយ៉ាងនេះក៏ដោយ អង្គការសង្គមស៊ីវិលបានសង្កេតឃើញថា រាជរដ្ឋាភិបាលកម្ពុជាមិនទាន់អនុវត្តគ្រប់សកម្មភាពចាំបាច់និងជាក់លាក់ក្នុងការជំរុញដំណើរការត្រួតពិនិត្យនិងកែទម្រង់ច្បាប់ពាក់ព័ន្ធដើម្បីអនុវត្តនូវអនុសាសន៍លើសិទ្ធិសូជីអេសស៊ី ដែលប្រទេសកម្ពុជាបានទទួលយកនៅជុំទី៣នៅឡើយទេ។ ភាគីពាក់ព័ន្ធដែលសង្គមស៊ីវិល**លើកទឹកចិត្ត គឺរដ្ឋដែលបានផ្តល់អនុសាសន៍យូ.ភី.អជុំទី៣ នឹងនៅតែផ្តល់អនុសាសន៍ទៅកាន់ប្រទេសកម្ពុជាលើសិទ្ធិសូជីអេសស៊ី និងសិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជនៅក្នុងយូ.ភី.អជុំទី៤ បន្តទៀត ដែលស្របនឹងអាទិភាពដែលសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាបានកំណត់** ( សូមមើល អនុសាសន៍អាទិភាពខាងក្រោម )។
- អនុសាសន៍ពាក់ព័ន្ធនឹងសិទ្ធិសូជីអេសស៊ី និងសិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជ ដែលផ្តល់មកប្រទេសកម្ពុជា ក្នុងជុំទី៤ នឹងជួយធានាការបន្តឱ្យមានវេទិកាសន្ទនាដោយវិជ្ជមានជាមួយភាគីពាក់ព័ន្ធ ដើម្បីជំរុញកិច្ចការពារសិទ្ធិស្មើគ្នារបស់អ្នកស្រឡាញ់ភេទដូចគ្នា (LGBT+) ដែលកន្លងមកបានអនុវត្តខ្លះៗក្នុងក្របខណ្ឌនៃអនុសាសន៍ដែលបានទទួលយកក្នុងយូ.ភី.អ ជុំទី៣។
- រាជរដ្ឋាភិបាលកម្ពុជាបានអញ្ជើញ អ្នកជំនាញឯករាជ្យរបស់អង្គការសហប្រជាជាតិទទួលបន្ទុកការពារប្រឆាំងនឹងអំពើហិង្សានិងការរើសអើងផ្អែកលើសិទ្ធិនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ (IE SOGI) ធ្វើទស្សនកិច្ចផ្លូវការមកកាន់ប្រទេសកម្ពុជាកាលពីខែមករា ឆ្នាំ២០២៣។ នៅក្នុងរបាយការណ៍បញ្ចប់បេសកកម្មរបស់ IE SOGI បានលើកទឹកចិត្តរាជរដ្ឋាភិបាលកម្ពុជាឱ្យបន្តវឌ្ឍនភាពស្របតាមការប្តេជ្ញាចិត្តលើបញ្ហាអាទិភាពចម្បងទាំង៣ក្នុងអនុសាសន៍ យូ.ភី.អជុំទី៣ រួមមាន ការទទួលស្គាល់ក្រុមគ្រួសារអ្នកស្រឡាញ់ភេទដូចគ្នាជាអាទិភាព តាមរយៈការទទួលស្គាល់ស្របច្បាប់ចំពោះគូស្រករភេទដូចគ្នា ការទទួលស្គាល់អត្តសញ្ញាណយេនឌ័រ ព្រមទាំងការបង្កើតច្បាប់និងគោលនយោបាយការពារពីការរើសអើងប្រកបដោយប្រសិទ្ធភាព។

## ទិដ្ឋភាពទូទៅនៃវឌ្ឍនភាពការអនុវត្តអនុសាសន៍ដែលបានទទួលយក កាលពី យូ.ភី.អជុំទី៣ ឧបសគ្គដែលនៅបន្ត និងអនុសាសន៍អាទិភាព សម្រាប់ យូ.ភី.អជុំទី៤

### សមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នា

- នៅក្នុង យូ.ភី.អជុំទី៣ ឆ្នាំ២០១៩ ប្រទេសកម្ពុជាបានទទួលយកអនុសាសន៍ចំនួន៣ ផ្តោតលើការវិសោធនកម្មច្បាប់ពាក់ព័ន្ធ ដើម្បីអនុញ្ញាតឱ្យមានសមភាពអាពាហ៍ពិពាហ៍សម្រាប់គូស្រករអ្នកស្រឡាញ់ភេទដូចគ្នា *(អនុសាសន៍លេខ ១១០.៥៥ ពីកាណាដា ១១០.៥១ ពីហូឡង់ និង១១០.៤៧ ពីអ៊ីស្លង់)*។
- បច្ចុប្បន្ន ច្បាប់នៃប្រទេសកម្ពុជាមិនមានបទបញ្ញត្តិជាក់លាក់ដែលទទួលស្គាល់អាពាហ៍ពិពាហ៍គូស្រករភេទដូចគ្នានៅឡើយទេ គូស្រករភេទដូចគ្នានៅប្រទេសកម្ពុជា ត្រូវបានបដិសេធពីកិច្ចការពារស្មើភាពគ្នានិងការរក្សាសន្តិសុខចាំបាច់ធានាដោយច្បាប់ប្រទេសកម្ពុជា ហើយមានតែសមភាពច្បាប់អាពាហ៍ពិពាហ៍ទេដែលអាចផ្តល់បាននូវការពារទាំងអស់នេះ។
- សមាជិកសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា បានបន្តកំណត់យកការទទួលបានសិទ្ធិសមភាពអាពាហ៍ពិពាហ៍ គឺជាអាទិភាពចម្បងដើម្បីការពារសិទ្ធិស្មើគ្នាក្នុង ផ្នែកអាពាហ៍ពិពាហ៍និងគ្រួសាររបស់ពួកគេ ដែលបូករួមទាំងការទទួលបានការការពារតាមប្រព័ន្ធច្បាប់ក្នុងនាមជាសហព័ទ្ធ និងជាសមាជិកគ្រួសារ (រួមមានសិទ្ធិសុំកូនពេញលេញ ដែលភ្ជាប់ជាមួយនឹងកិច្ចការពារសំខាន់ៗចំពោះទំនាក់ទំនងរវាងឪពុកម្តាយ អាណាព្យាបាល និងកូន ផ្សាភ្ជាប់ទៅនឹងឧត្តមប្រយោជន៍របស់កុមារ) ក៏ដូចជាចូលរួមចំណែកកាត់បន្ថយនិងលុបបំបាត់ការរើសអើងកម្រិតខ្ពស់ដែលពួកគេជួបប្រទះ។
- សារៈសំខាន់នៃវឌ្ឍនភាពឈានទៅកាន់ការទទួលស្គាល់ផ្នែកច្បាប់ចំពោះគ្រួសារអ្នកស្រឡាញ់ភេទដូចគ្នា(LGBT+) តាមរយៈការទទួលស្គាល់ច្បាប់សមភាព អាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នា ហើយក៏ត្រូវបានអ្នកជំនាញឯករាជ្យរបស់អង្គការសហប្រជាជាតិទទួលបន្ទុកការពារប្រឆាំងនឹងអំពើហិង្សា និងការរើសអើងផ្អែកលើសិទ្ធិនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ (IE SOGI) ទទួលស្គាល់ក្នុងអំឡុងពេលទស្សនកិច្ចផ្លូវការរបស់គាត់

មកកាន់ប្រទេសកម្ពុជាកាលពី ខែមករា ឆ្នាំ២០២៣ ផងដែរ ដោយបានកត់សម្គាល់ថា *«ការទទួលស្គាល់ដោយច្បាប់ចំពោះគ្រួសារអ្នកស្រឡាញ់ភេទដូចគ្នាគឺជាគន្លឹះនៃសមាហរណកម្មក្នុងសង្គម»* និងលើកទឹកចិត្តប្រទេសកម្ពុជា បន្តភាពរីកចម្រើននេះជាអាទិភាពទៅកាន់ «ការទទួលស្គាល់ក្រុមគ្រួសារអ្នកស្រឡាញ់ភេទដូចគ្នាតាមរយៈការទទួលស្គាល់អាពាហ៍ពិពាហ៍គូស្រករភេទដូចគ្នា។»

- ចាប់តាំងពីឆ្នាំ២០១៩មក អង្គការសង្គមស៊ីវិលសង្កេតឃើញថា រាជរដ្ឋាភិបាលកម្ពុជាបានចូលរួមក្នុងការពិភាក្សាជាមួយសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា (LGBT+) និងអង្គការសង្គមស៊ីវិល ដែលមានលក្ខណៈស្ថាបនា អំពីផែនការបន្តជំរុញសមភាពច្បាប់អាពាហ៍ពិពាហ៍ ស្របតាមអនុសាសន៍ យូ.ភី.អជុំទី៣ ដែលបានទទួលយក ហើយចំណុចនេះបានបង្កើតជាជំហានវិជ្ជមាន(រួមមានកិច្ចសន្ទនាតុមូលក្នុងកម្មវិធីសម្ពោធយុទ្ធនាការសមភាពអាពាហ៍ពិពាហ៍ "ខ្ញុំទទួលយក" និងនៅក្នុងកម្មវិធីកិច្ចសន្ទនាឆ្នាំ២០២២ ស្តីពីរបាយការណ៍ពាក់កណ្តាលអាណត្តិ យូ.ភី.អជុំទី៣។
- ទោះជាយ៉ាងណាក៏ដោយ គិតមកត្រឹមខែកញ្ញា ឆ្នាំ២០២៣ រាជរដ្ឋាភិបាលកម្ពុជាមិនទាន់មានសកម្មភាពជាក់លាក់ក្នុងការជំរុញដំណើរការពិនិត្យនិងវិសោធនកម្មច្បាប់ដែលចាំបាច់ដើម្បីអនុវត្តអនុសាសន៍ទាំង៣ នៅក្នុងយូ.ភី.អ ជុំទី៣ ដែលប្រទេសកម្ពុជាបានទទួលយក ដែលផ្តោតលើការអនុញ្ញាតឱ្យមានសមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នានៅឡើយទេ។

| | |
|---|---|
| →អនុសាសន៍អាទិភាពមកកាន់កម្ពុជាសម្រាប់ យូ.ភី.អជុំទី៤ | ១. **បន្តវឌ្ឍនភាពនៃការធ្វើវិសោធនកម្មច្បាប់ ដើម្បីទទួលស្គាល់សមភាពអាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នា (LGBT+) ដោយមានការធានានូវការមិនរើសអើង សមភាពពេញលេញ និងបរិយាប័ន្នសង្គមសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជា** ស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព "មិនទុកនរណាម្នាក់ចោល" និងអនុសាសន៍បានផ្តល់ដោយអ្នកជំនាញឯករាជ្យរបស់អង្គការសហប្រជាជាតិទទួលបន្ទុកការពារប្រឆាំងនឹងអំពើហិង្សានិងការរើសអើងផ្អែកលើសិទ្ធិនិន្នាការភេទ និង អត្តសញ្ញាណយេនឌ័រ (IE SOGI) ។ |

## ច្បាប់ទទួលស្គាល់អត្តសញ្ញាណយេនឌ័រ

- នៅក្នុងយូ.ភី.អជុំទី៣ ប្រទេសកម្ពុជាបានទទួលយកអនុសាសន៍មួយដែលស្តីពីការអនុញ្ញាតឱ្យមានការទទួលស្គាល់អត្តសញ្ញាណយេនឌ័រស្របច្បាប់សម្រាប់អ្នកប្តូរយេនឌ័រ (transgender persons) *(អនុសាសន៍ ១១០.៥៤ ពីអ៉ីស្លង់ )*។
- ភាពមិនទាន់មានការទទួលស្គាល់ផ្នែកច្បាប់ នៃការកំណត់អត្តសញ្ញាណយេនឌ័រដោយបុគ្គលនៅលើឯកសារផ្លូវច្បាប់ បង្កើនឱ្យមានការផាត់ចេញពីសង្គមនិងបទពិសោធនៃការរើសអើងរបស់អ្នកប្តូរយេនឌ័រ និងអ្នកដែលមានយេនឌ័រចម្រុះក្នុងប្រទេសកម្ពុជា។
- ចាប់តាំងពីឆ្នាំ២០១៩មក អង្គការសង្គមស៊ីវិលសង្កេតឃើញថា រាជរដ្ឋាភិបាលកម្ពុជាបានចូលរួមក្នុងកិច្ចសន្ទនាជាមួយភាគីសង្គមស៊ីវិលអំពីវឌ្ឍនភាពនៃការទទួលស្គាល់អត្តសញ្ញាណយេនឌ័រស្របតាមអនុសាសន៍យូ.ភី.អជុំទី៣ ដែលបានទទួលយក ហើយបង្កើតនូវជំហានបឋម ដែលគួរឱ្យជាទីមោទន។ ទោះជាយ៉ាងនេះក្តី រាជរដ្ឋាភិបាលកម្ពុជាមិនទាន់មានសកម្មភាពជាក់លាក់ក្នុងការជំរុញដំណើរការពិនិត្យច្បាប់និងគោលនយោបាយ ដែលអនុញ្ញាតការទទួលស្គាល់អត្តសញ្ញាណយេនឌ័រកំណត់ដោយបុគ្គលផ្ទាល់ ស្របតាមស្តង់ដារច្បាប់សិទ្ធិមនុស្សអន្តរជាតិនៅឡើយទេ។

| | |
|---|---|
| →អនុសាសន៍អាទិភាពមកកាន់កម្ពុជាសម្រាប់ យូ.ភី.អជុំទី៤ | ២. **ពិនិត្យច្បាប់និងគោលនយោបាយពាក់ព័ន្ធ ដែលអនុញ្ញាតឱ្យមានការទទួលស្គាល់ផ្នែកច្បាប់ស្តីពីការកំណត់អត្តសញ្ញាណយេនឌ័រដោយបុគ្គលស្របតាមស្តង់ដារច្បាប់សិទ្ធិមនុស្សអន្តរជាតិ** និងស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព "មិនទុកនរណាម្នាក់ចោល" និងជាអនុសាសន៍បានផ្តល់ដោយអ្នកជំនាញឯករាជ្យរបស់អង្គការសហប្រជាជាតិទទួលបន្ទុកការពារប្រឆាំងនឹង អំពើហិង្សានិងការរើសអើងផ្អែកលើសិទ្ធិនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ (IE SOGI)។ |

## មធ្យោបាយការពារការរើសអើងផ្អែកលើសូជីអេសស៊ីដែលមានប្រសិទ្ធភាពរួមមាន ការការពារផ្នែកច្បាប់និងគោលនយោបាយ

- នៅក្នុងយូ.ភី.អជុំទី៣ ប្រទេសកម្ពុជាបានទទួលយកអនុសាសន៍ចំនួន៥ក្នុងការបង្កើតច្បាប់ គោលនយោបាយ និងយន្តការដែលមានប្រសិទ្ធភាពក្នុងការការពារអ្នកស្រឡាញ់ភេទដូចគ្នាពីការរើសអើងនិងអំពើហិង្សាផ្អែកលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ (សូជីអេសស៊ី) *(អនុសាសន៍លេខ១១០.៤៥ ពីអ៉ីស្លង់ ១១០.៥២ ពីស៊ុយអ៊ែត ១១០.៥៤ ពីអូស្ត្រាលី ១១០.៥០ ពីម៉ិចស៊ីកូ. ១១០.៥៣ ពីអ៊ុយរូហ្គាយ)*។
- ចាប់តាំងពីឆ្នាំ២០១៩ មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់និងកោតសរសើរមួយចំនួនហើយជាជំហានដំបូងនៃការណែនាំអំពីមធ្យោបាយទូទៅនិងគោលនយោបាយការពារពីការរើសអើងផ្អែកលើសូជីអេសស៊ី រួមមាន៖
    - វឌ្ឍនភាពនៃការសម្រេចបាននូវកម្មវិធីសិក្សាសាលារដ្ឋស្តីពីការអប់រំផ្លូវភេទគ្រប់ជ្រុងជ្រោយដែលបានបញ្ចូលគោលគំនិតសូជីអេសស៊ី។
    - ការរួមបញ្ចូលស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរយេនឌ័រនៅក្នុងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (២០១៩-២០២៣)។

- សេចក្តីអំពាវនាវជាសាធារណៈពីសំណាក់ប្រមុខ និងមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា លើកទឹកចិត្តមន្ត្រីរដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឪពុកម្តាយ និងក្រុមគ្រួសាររបស់អ្នកស្រឡាញ់ភេទដូចគ្នា ប្រព័ន្ធផ្សព្វផ្សាយ ក៏ដូចជាសាធារណជនទូទៅ មិនឱ្យរើសអើងលើ អ្នកស្រឡាញ់ភេទដូចគ្នា។
- បង្កើនការលើកកម្ពស់ការយល់ដឹងជាសាធារណៈនិងការទទួលយកអ្នកស្រឡាញ់ភេទដូចគ្នា នេះជាលទ្ធផលមួយផ្នែកនៃសកម្មភាពលើកកម្ពស់ ការផ្សព្វផ្សាយការយល់ដឹងរបស់ភាគីសង្គមស៊ីវិលសហការជាមួយប្រព័ន្ធផ្សព្វផ្សាយ អាជ្ញាធរថ្នាក់មូលដ្ឋាននិងថ្នាក់ជាតិ។

- ទោះជាមានវឌ្ឍនភាពនៃការទទួលយកអ្នកស្រឡាញ់ភេទដូចគ្នា និងមានជំហានជាបន្តបន្ទាប់ ដែលរាជរដ្ឋាភិបាលអនុវត្តក្នុងការបង្កើតជាមធ្យោបាយមួយចំនួនដើម្បីដោះស្រាយនិងការពារពីការរើសអើងផ្អែកលើសូជីអេសស៊ីនាអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយចាប់តាំងពីឆ្នាំ២០១៩ក្តី ក៏អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជានៅតែបន្តជួបប្រទះការរើសអើងផ្អែកលើសូជីអេសស៊ី ក្នុងផ្នែកជាច្រើននៅក្នុងសង្គម រួមមានគ្រួសារ ការងារ ការអប់រំ និងសុខភាពដែលជាឧបសគ្គរាំងសមភាពនិងបរិយាប័ន្នសង្គម។ (សូមមើលព័ត៌មានលម្អិតនៅក្នុងរបាយការណ៍ពេញ)។ ម៉្យាងទៀត រាជរដ្ឋាភិបាលកម្ពុជាក៏មិនទាន់មានសកម្មភាពជាក់លាក់ ក្នុងការជំរុញដំណើរការកែទម្រង់ច្បាប់ និងគោលនយោបាយដែលហាមប្រាមជាក់លាក់ ទៅលើការរើសអើងនិងអំពើហិង្សាផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ឬទៅលើអ្នកស្រឡាញ់ភេទដូចគ្នា ក្នុងគ្រប់វិស័យទាំងអស់នៅឡើយទេ។

| | |
|---|---|
| →អនុសាសន៍អាទិភាពមកកាន់កម្ពុជាសម្រាប់ យូ.ភី.អជុំទី៤ | ៣. បន្តកិច្ចខិតខំប្រឹងប្រែងធ្វើការជាមួយគ្រប់ភាគី រួមទាំងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានិងស្ថាប័នសង្គមស៊ីវិល ដើម្បីបង្កើតមធ្យោបាយ ដែលធានានូវកិច្ចការពារពីការរើសអើស ផ្អែកលើនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ ស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព "មិនទុកនរណាម្នាក់ចោល" ។ |
| | ៤.ធានានូវការរួមបញ្ចូលនិងកិច្ចការពារអ្នកស្រឡាញ់ភេទដូចគ្នា(LGBT+) និង អ្នកមាននិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រចម្រុះ នៅក្នុងច្បាប់និងគោលនយោបាយពាក់ព័ន្ធ ដែលការពារពីការរើសអើងនិងអំពើហិង្សាផ្អែកលើយេនឌ័រ (ជាពិសេសនៅគ្រឹះស្ថានអប់រំ កន្លែងការងារ ការថែទាំសុខភាព និងទីសាធារណៈ) ស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព "មិនទុកនរណាម្នាក់ចោល" (និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពលេខ៥ លេខ១០.៣ និងលេខ១៦.ខ)ក៏ដូចជាអនុសាសន៍ របស់អ្នកជំនាញឯករាជ្យរបស់អង្គការសហប្រជាជាតិទទួលបន្ទុកការពារប្រឆាំង នឹងអំពើហិង្សានិងការរើសអើងផ្អែកលើសិទ្ធិនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ (IE SOGI) ។ |

*របាយការណ៍រួមពេញបានបង្ហាញនូវជំហាននៃអនុសាសន៍ជាក់លាក់និងលម្អិតស្នើឡើងជាផែនទីនៃការអនុវត្តអនុសាសន៍អាទិភាពសម្រាប់ដំណើរការយន្តការ យូ.ភី.អ ជុំទី៤។*

សូមមើលរបាយការណ៍ពេញសម្រាប់ព័ត៌មានលម្អិត៖
"សេចក្តីស្នើរួមរបស់អង្គការសង្គមស៊ីវិល ទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សម្រាប់យន្តការត្រួតពិនិត្យឡើងវិញជាសកល តាមកាលកំណត់ (យូ ភី អ) ជុំទី៤ នៃព្រះរាជាណាចក្រកម្ពុជាអំពី សិទ្ធិសូជីអេសស៊ី និងសិទ្ធិសុខភាពផ្លូវភេទ និងបន្តពូជ"(ខែតុលា ឆ្នាំ ២០២៣)។

**សូមទំនាក់ទំនងអំពីរបាយការណ៍រួម យូ.ភី.អជុំទី៤តាមរយៈ ៖** លី ពិសី ប្រធានសម្របសម្រួលអង្គការសហគមន៍ឥន្ទធនូកម្ពុជា (រ៉ក់)
**អ៊ីម៉ែល៖** pisey@rockcambodia.org **គេហទំព័រ៖** http://www.rockcambodia.org/.